ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៧..សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារ ដឹកនាំការវាយតំលៃផលប៉ះពាល់ខាងបរិស្ថាន និងសង្គម សំរាប់គំរោងសាងសង់រោងចក្រប្រេងកាត នៅភូមិព្រែកទាល់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតក្រុមការងារ ដើម្បីដឹកនាំការវាយតំលៃផលប៉ះពាល់ខាងបរិស្ថាន និងសង្គម សំរាប់គំរោងសាងសង់ រោងចក្រប្រេងកាត នៅភូមិព្រៃកទាល់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

**ប្រការ ២.**

ក្រុមការងារនេះ មានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| ១- ឯកឧត្តម **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២- ឯកឧត្តម **សុខ ចិន្តាសោភា** អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣- ឯកឧត្តម **ទី តាឃី** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម **គោស៊ុំ សារឿត** រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៥- ឯកឧត្តម **ប្រាក់ ហាម** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- ឯកឧត្តម **សាត សាមី** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៧- ឯកឧត្តម **ប៊ុន ហ៊ាន** រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៨- ឯកឧត្តម **ស្បោង សារ៉ាត** អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ៩- ឯកឧត្តម **សុខ ខាន់ម៉ាន់** អគ្គនាយក អាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |

**ប្រការ ៣.**

ក្រុមការងារនេះ មានភារកិច្ច ដូចខាងក្រោម ៖

- ដឹកនាំ និងណែនាំដល់ម្ចាស់ក្រុមហ៊ុន ដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គម សំរាប់គំរោងសាងសង់រោងចក្រប្រេងកាត នៅភូមិព្រៃកទាល់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យ និងឯកសារពាក់ព័ន្ធជាមួយនឹងទីតាំងគំរោង
- ប្រជុំបូកសរុប ធ្វើរបាយការណ៍ពេញលេញ និងលើកយោបល់ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច ។

**ប្រការ ៤..**

សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធានក្រុមការងារ ។

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ។

**ប្រការ ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ដូចមានក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*